គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៤៦ ចេញផ្សាយថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២
No. 46 Released on May 20, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ប្រភេទនៃបរធនបាលកិច្ចនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន

## Types of Trust Currently Available in Cambodia




https://utltrustees.com/2020/10/27/do-you-know-the-various-types-of-trusts/

មកទល់បច្ចុប្បន្ននេះ នៅកម្ពុជាមានបរធនបាលកិច្ចចំនួន ៥ ប្រភេទដូចខាងក្រោម÷

១. បរធនបាលកិច្ចហិរញ្ញវត្ថុ សំដៅដល់មូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុល ដែលដៃគូអភិវឌ្ឍន៍ផ្តល់ឱ្យរដ្ឋាភិបាល ដែលកំពុងត្រូវបានគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យធនាគារនិងវិស័យមីក្រូហិរញ្ញវត្ថុ។

២. បរធនបាលកិច្ចសាធារណៈ សំដៅដល់បរធនបាលកិច្ចដែលត្រូវបានបង្កើតឡើង ដើម្បីជាប្រយោជន៍សាធារណៈ ដល់ប្រជាជនខ្មែរទូទៅ (ឧទាហរណ៍ មូលនិធិគន្ធបុប្ផា)។

៣. បរធនបាលកិច្ចពាណិជ្ជកម្ម សំដៅដល់បរធនបាលកិច្ចដែលត្រូវបានបង្កើតឡើង ដើម្បីស្វែងរកប្រាក់ចំណេញ។

៤. បរធនបាលកិច្ចសង្គម សំដៅដល់បរធនបាលកិច្ចដែលត្រូវបានបង្កើតឡើង ដោយបរធនបាលនាយកតាមរយៈការធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួន ទៅឱ្យបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គមដូចជា ក្នុងគោលបំណងវប្បធម៌ អប់រំ មនុស្សជាតិ សាសនា វិទ្យាសាស្ត្រ ជាដើម។

៥. បរធនបាលកិច្ចបុគ្គល សំដៅដល់បរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងដើម្បីជាប្រយោជន៍បុគ្គល មានដូចជា ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យបរធនបាល ដើម្បីជាប្រយោជន៍បុគ្គល, ការផ្ទេរទ្រព្យសម្បត្តិនៅពេលមានជីវិត ឬមរតកសាសន៍ ជាដើម។

To present, there are 5 types of trust in Cambodia:

1. Financial Trust refer to grant fund or sub-loan that development partners provided to the government being managed and used to support the development of the banking and microfinance sectors.

2. Public Trust refer to the trust that is established for the public benefit of Cambodian citizens. (Ex. Kantha Bopha Foundation).

3. Commercial trust refer to the trust that is established for profit gain.

4. Social Trust refer to the trust that is established when a trust creator contributes his asset to the trustee for general social purposes such as cultural, educational, human, religious, or scientific purposes.

5. Personal Trust refer to the trust that is established for his/her own personal interest such as to contributes his/her asset to the trustee for his/her personal interest, transferring of asset when alive or to create inheritance.

**អត្ថបទ÷ កេត ស្រីនិច | Article: Ket Sreynich**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ (២០១៣)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.